លីកាដូ

LICADHO

សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

**Cambodian League for the Promotion and Defense of Human Rights**

# កម្មវិធីបំប៉នសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋ



# HUMAN RIGHTS IMPROVEMENT TRAINING PROGRAM FOR PEOPLE

សំរាប់សិក្ខាកាម

FOR PARTICIPANTS

# កម្មវិធីបំប៉នសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋ

## ១.បុព្វកថា :

សៀវភៅនេះរៀបចំឡើងដើម្បីបំប៉នឬបង្កើនការយល់ដឹងអំពី *"សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ"* ដល់ប្រជាពលរដ្ឋនានានៅតាមសហគមន៍ ក្នុងន័យឱ្យប្រជាពលរដ្ឋចេះធ្វើការវិភាគសិទ្ធិមនុស្ស ឱ្យកាន់តែស៊ីជំរៅ និងជាពិសេស សំដៅដល់ការជួយចូលរួមដោះស្រាយការរំលោភសិទ្ធិមនុស្សដែលបាននិងកំពុងកើតឡើង ព្រោះអំពើទាំងនោះនៅតែរីករាលដាលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ម្យ៉ាងវិញទៀតគឺមានតែប្រជាពលរដ្ឋនេះហើយដែលជាភ្នាក់ងារ និង ជាកម្លាំងយ៉ាងសំខាន់សំរាប់កែប្រែគ្រប់ស្ថានភាព នៅក្នុងសង្គមជាតិទាំងមូល ។

## ២.គោលបំណង :

<u>នៅចុងបញ្ចប់នៃវគ្គ</u>

1.*អ្នកចូលរួមនឹងឯកភាពថា អ្វីដែលកំពុងតែសិក្សានិងពិភាក្សានៅក្នុងកម្មវិធីនេះ គឺជារឿងពិតដែលទាក់ទងផ្ទាល់ទៅនឹងសន្តិសុខ និងជីវភាពរស់នៅរបស់ពួកគាត់យ៉ាងពិតប្រាកដមែន។*

2.<u>សង្ឃឹមថាអ្នកចូលរួម:</u>

*ក).ប្រាកដជាពេញចិត្តនឹងបង្កើតជាក្រុមស៊ីវិល (ឬក្រុមការងារ) ជាក់លាក់មួយ សំរាប់ជួយអប់រំនិងពន្យល់សិទ្ធិមនុស្សនៅក្នុងមូលដ្ឋាន (ភូមិ,ឃុំ) របស់ពួកគាត់ ដើម្បីឱ្យមានការគោរពសិទ្ធិមនុស្សនិងច្បាប់។*

*ខ).នឹងអនុវត្តតួនាទីតាមរយៈក្រុមស៊ីវិលរបស់ពួកគាត់ ដើម្បីសហការដោះស្រាយអំពើរំលោភសិទ្ធិមនុស្សដែលកើតមាននៅក្នុងមូលដ្ឋាន និងបញ្ជូនឬផ្តល់ព័ត៌មានពីករណីរំលោភសិទ្ធិមនុស្សទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធ។*

## ៣.វិធីដំណើរការនៃវគ្គ :

កម្មវិធីសិក្សានៃវគ្គនេះទាំងមូលគឺផ្តោតសំខាន់ទៅលើការពិភាក្សាផ្តល់យោបល់គ្នាទៅវិញទៅមកដើម្បីរកដំណោះស្រាយអំពើរំលោភសិទ្ធិមនុស្សឬក៏បង្កើតជាយុទ្ធសាស្ត្រការពារសិទ្ធិមនុស្សនៅក្នុងមូលដ្ឋាន។ដូច្នេះបានន័យថាវគ្គសិក្សានេះគឺជាការបង្កើតក្រុមពិភាក្សាទៅលើករណីសិក្សាជាច្រើនក៏ដូចជាលំហាត់ពិភាក្សាឬសំនួរផ្សេងៗហើយនិងមានការសំដែងឆាកផងដែរ។

*-វគ្គបំប៉ននេះរំពឹងទុកថាអ្នកចូលរួមទាំងអស់នឹងបញ្ចេញមតិយ៉ាងផុលផុសនិងពេញទំហឹងដើម្បីរកឱ្យឃើញនូវវិធានការសំរាប់ការពារ និងធ្វើយ៉ាងណាដើម្បីកាត់បន្ថយអំពើរំលោភសិទ្ធិមនុស្សឱ្យមានប្រសិទ្ធិភាព។*

*-វគ្គបំប៉ននេះ អ្នកសំរបសំរួលវគ្គត្រូវរៀបចំល្បែងស្វាងគំនិត យ៉ាងហោចណាស់ក្នុង១ថ្ងៃឱ្យបាន១ល្បែងតាមការជ្រើសរើស*

*-នៅចុងបញ្ចប់នៃវគ្គ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យធ្វើការវាយតំលៃទៅលើលទ្ធផលទូទៅរបស់វគ្គទាំងមូល។*

# មាតិកា


| លេខរៀង | ឈ្មោះឯកសារ | ទំព័រ |
|---|---|---|
| ១ | ✪ សិទ្ធិក្នុងឋានៈជាមនុស្ស<br>1-ទស្សនៈសិទ្ធិមនុស្ស<br>2-ករណីសិក្សានិងលំហាត់<br>3-ឧបសម្ព័ន្ធ | ១-៧ |
| ២ | ✪ សិទ្ធិឱ្យមានការយកចិត្តទុកដាក់ពីរដ្ឋនិងសង្គម<br>1-ទស្សនៈសិទ្ធិមនុស្ស<br>2-ករណីសិក្សា<br>3-ឧបសម្ព័ន្ធ | ៨-១៤ |
| ៣ | ✪ ប្រជាពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ<br>1-ទស្សនៈសិទ្ធិមនុស្ស<br>2-លំហាត់និងករណីសិក្សា<br>3-ឧបសម្ព័ន្ធ | ១៥-២២ |
| ៤ | ✪ សិទ្ធិបុគ្គល/ឯកជនរបស់ប្រជាពលរដ្ឋ<br>1-ទស្សនៈសិទ្ធិមនុស្ស<br>2-សំនួរពិភាក្សានិងករណីសិក្សា<br>3-ឧបសម្ព័ន្ធ | ២៣-២៧ |
| ៥ | ✪ ស្ត្រីនិងការអភិវឌ្ឍន៍<br>1-ទស្សនៈសិទ្ធិមនុស្សនិងយេនឌ័រ<br>2-សំនួរពិភាក្សា<br>3-ឧបសម្ព័ន្ធ | ២៨-៣៤ |
| ៦ | ✪ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ<br>1-ទស្សនៈរូម<br>2-ពិភាក្សាលំហាត់<br>3-នីតិវិធីក្នុងការចុះស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស | ៣៥-៤០ |

# សិទ្ធិក្នុងឋានៈជាមនុស្ស

## I.ទស្សនៈសិទ្ធិមនុស្ស

មនុស្សទាំងអស់កើតមកសុទ្ធតែមានសេចក្ដីត្រូវការដូចៗគ្នា ស្មើៗគ្នាតាំងពីកំនើត ឬតាំងតែពីកើតមក ដោយគ្មាននរណាម្នាក់ខ្វះបានឡើយ ឬក៏មិនមាននរណាម្នាក់ទទួលបានពីធម្មជាតិជាមនុស្ស នូវសេចក្ដីត្រូវការសំរាប់ទ្រទ្រង់ជីវិតលើសគេលើសឯងឬខុសខ្វាតពីគេពីឯង ដោយមិនគិតថា ជាមនុស្សគរ ថ្លង់ ឬឆ្កួតនោះឡើយ ។តាមលក្ខខណ្ឌធម្មជាតិ មនុស្សកើតមកប្រកបទៅដោយចលនាព្រម រស់រវើកជាប់មកជាមួយនឹងខ្លួនដោយស្វ័យប្រវត្តិ ដូចជា ត្រូវការហូប ត្រូវការដើរ និយាយ ទំនាក់ទំនង សើចយំ ។ល ។បានន័យថាមនុស្សមានវិចារណញ្ញាណ មានសតិសម្បជញ្ញៈ មានតំលៃនិងសេចក្ដីថ្លៃថ្នូរស្មើៗគ្នាក្នុងនាមជាមនុស្ស ។ល ។ក៏ប៉ុន្តែនៅក្នុងសង្គមនៃមនុស្សគ្រប់ជំនាន់ នៅពេលដែលមនុស្សខ្លះ ត្រូវបានគេប្រគល់តួនាទីនិងអំណាច សំរាប់គ្រប់គ្រងសំរាប់ការពារសុវត្ថិភាពសង្គមឬរបៀបរៀបរយសាធារណៈ មនុស្សទាំងនោះ បែរជាមើលងាយមើលថោកមនុស្សដូចគ្នា បែរជាជេរប្រមាថ វាយដំច្រំធាក់ កាប់សំលាប់គ្នាឥតត្រាប្រណី ឬក៏មានទស្សនៈប្រកាន់តឹងថា មនុស្សណាមានកំហុស ត្រូវតែទទួលនូវអំពើហិង្សា ដោយមិនគិតថា ពួកគេទាំងនោះ ជាមុស្សដូចខ្លួននោះទេ ហើយជួនកាល ឆ្លៀតយកឱកាសសិទ្ធិអំណាចទាំងនោះ ទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួន គំនុំផ្ទាល់ខ្លួន ឬក៏បំរើឱ្យបក្សពួកខ្លួន ។ល ។ហើយទោះបីជាពេលនេះ ល័ក្ខខ័ណ្ឌច្បាប់ បានការពារ និងគោរពនូវសិទ្ធិមនុស្សយ៉ាងណាក៏ដោយ ។ហេតុដូច្នេះហើយ បានជាធ្វើឱ្យសង្គមជាតិ មានភាពច្របូកច្របល់ អ្នកនេះឆ្លើយដាក់អ្នកនោះ អ្នកនោះឆ្លើយដាក់អ្នកនេះ មិនចេះអស់មិនចេះហើយ តែអំពើរលោភ អំពើល្មើស នៅតែកើតមានជាប្រចាំ ទីបំផុត ភាពអយុត្តិធមិនៅតែផ្តល់ឱ្យជនរងគ្រោះជានិច្ច ។

## II.ករណីសិក្សា

**លំហាត់ទី១** : ប៉ូលីសចាប់បានចោរម្នាក់ ឈ្មោះសាយ ពីបទចោរកម្ម ។គេបានឃើញបុរសនេះត្រូវប៉ូលីសនិងអ្នកស្រុកកំពុងតែវាយដំយ៉ាងខ្លាំងរហូតដល់សន្លប់ ។បងប្អូនអ្នកភូមិ ភាគច្រើនត្រេកអរណាស់ មានតែយាយ តា ២-៣នាក់ប៉ុណ្ណោះដែលអាណោចអាធ័ម ។ពេលនោះស្រាប់តែមានភ្នាក់ងារសិទ្ធិមនុស្សសំណូមពរទៅប៉ូលីសកុំឱ្យធ្វើដូច្នេះ ។ប៉ូលីសបដិសេធហើយនិយាយថា " អញ្ចឹងហើយបានជាគេថាសិទ្ធិមនុស្សកាន់ជើងចោរ " បងប្អូនអ្នកស្រុកខ្លះក៏បន្ទរតាមដែរ ហើយនិយាយថា *បើមិនធ្វើដូច្នេះ ម៉េចរាងា ។*

នេះជាការគោរពសិទ្ធិមនុស្សនិងច្បាប់



នេះគឺជាអំពើរំលោភសិទ្ធិមនុស្សនិងច្បាប់



ក្រោយមកបុរសនេះត្រូវស្លាប់ដោយជំងឺក្រុំ ( ធ្លាក់ឈាម ) ហើយបានបន្សល់ភរិយានិងកូន៥នាក់ឱ្យនៅឯកោ ។ បន្ទាប់មក នៅតែមានអ្នកគាំទ្រថា ស្លាប់អញ្ចឹងវាសមហើយ កុំឱ្យគេយកគំរូតាមទៀត ។

***ពិភាក្សា**

| សំនួរបំផុសបញ្ហា | សំណួររកដំណោះស្រាយ | អនុសាសន៍ឬសំណូមពរ |
|---|---|---|
| 1-តើមានបញ្ហាអ្វីខ្លះកំពុងកើតឡើងតាមករណីសិក្សាខាងលើនេះ?<br>2-តើនៅក្នុងស្រុកភូមិរបស់គេៗធ្លាប់ជួបធ្លាប់ចូលរួម ហេតុការណ៍ដូច្នេះទេ?<br>3-នៅពេលដែលប៉ូលីសចាប់បានចោរត្រូវតែមានការវាយដំដូច្នេះ ទើបបានសម ព្រោះជាមនុស្សខូច ។ តើពួកគេឯកភាពឬមិនឯកភាពទៅនឹងអំពើទារុណកម្មខាងលើនេះ? ហេតុអ្វី?<br>4-តើអ្នកចូលរួមយល់ឃើញដូចម្តេចដែរ នៅពេលដែលភ្នាក់ងារសិទ្ធិមនុស្សធ្វើអន្តរាគមន៍ទៅប៉ូលីសដូច្នេះ? ត្រឹមត្រូវឬមិនត្រឹមត្រូវ? ហេតុអ្វី? | 1-តើមានច្បាប់និយាយពីរឿងចោរលួចចោរប្លន់នេះដែរឬទេ? មានច្បាប់ណាខ្លះ<br>2-តើអ្នកណាមានកំហុសរវាងអង្គការសិទ្ធិមនុស្សនិងប៉ូលីស? ហេតុអ្វី?<br>3-បើភាគីណាមួយមានកំហុស តើត្រូវទទួលទោសដែរឬទេ? បទល្មើសអ្វី?<br>4-តើវាជាការពិតឬមិនពិតដែលអ្នកលួចប្លន់ខ្លះត្រូវបានគេដោះលែងឱ្យមានសេរីភាពក្រោយពីបានជាប់ឃុំតែមួយរយៈពេលខ្លីនោះ? តើអ្នកណាជាអ្នកដោះលែងឬជាអង្គការសិទ្ធិមនុស្ស? | តាមខ្លឹមសារករណីសិក្សា ជនជាប់ចោទបានស្លាប់ដោយជំងឺក្រុំធ្លាក់ឈាម តើ:<br>1-មានវិធានឬយុទ្ធសាស្ត្រអ្វី ដើម្បីលុបបំបាត់អំពើទារុណកម្មនេះទេ?<br>2-តើមានអ្នកណាខ្លះចូលរួម ជួយកែប្រែស្ថានភាពនេះបាន និងមានប្រសិទ្ធិភាព? |

<u>**លំហាត់ទី២**</u> : អ្នកស្រុកម្នាក់បាននិយាយថា ស្រុកស្រែចំការយើងឥឡូវមានចោរលួចចោរប្លន់ច្រើនណាស់ ពេលយប់ឡើងភ័យព្រួយ អ្នកខ្លះព្រលប់មិនទាន់ បិទទ្វារចាក់សោរផ្ទះ ។ប៉ុន្តែថ្មីៗនេះ ពួកវាចាប់ជំរិតកសិករយើងទាំងថ្ងៃទៅទៀត នៅពេលដែលពួកគេកំពុងច្រូតស្រូវ ហើយពួកវាកំណត់យកមួយលានរៀលម្នាក់ បើអ្នកណាមិនឱ្យវាសំលាប់ចោល ។ចំណែករឿងមួយទៀតដែលគួរឱ្យព្រួយបារម្ភដែរនោះ គឺការចាប់ពង្រត់មនុស្សយកទៅលក់ក៏មានជាប្រចាំដែរ គឺពួកវាប្រើគ្រប់ល្បិចកល ជាពិសេសយើងរាល់គ្នាដែលមានកូនស្រីត្រូវតែប្រុងប្រយត្ន័ឱ្យមែនទែន ។

អ្នកស្រុកនោះដកដង្ហើមធំហើយនិយាយថា យើងហាក់ដូចជារងារណាស់សព្វថ្ងៃនេះ ព្រោះយើងដៃទទេ ហើយមិនដឹងថាធ្វើដូចម្ដេចទេ! ។កសិករនោះបន្ដថា តែបើនិយាយតាមសំដីប៉ូលីសខ្លះ ឬកងសេនាជនខ្លះ គេតែងពោលថា ប្រាក់ខែបើកមក ចាយមិនបាន ៤-៥ថ្ងៃផង ទៅរស់ពាំងទ្រូងធ្វើអី! ស្លាប់ឥតអំពើ ដេកផ្ទះស្រួលជាង ។ហើយបើតាមពាក្យចចាមអារ៉ាមខ្លះថា ប្រហែលជាមានប៉ូលីសខ្លះ ឬកងសេនាជនខ្លះ ចូលដៃចូលជើង ជាមួយផងក៏មិនដឹង ។

•ពិភាក្សា

| សំនួរបំផុសបញ្ហា | រកដំណោះស្រាយ | អនុសាសន៍ឬសំណូមពរ |
|---|---|---|
| 1-តើពួកគេកំពុងប្រឈមមុខទៅនឹងបញ្ហាអ្វីខ្លះ?<br>2-តើពួកគេឯកភាពថា វាជាបញ្ហាពិតមែន ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរស់នៅរបស់ពួកគេដែរឬទេ?(ឱ្យពួកគេលើកពីឧប្បត្តិហេតុខ្លះមកបញ្ជាក់) ។<br>3-តើបញ្ហាដែលកើតមានដូច្នេះគេគិតថា វាជាបញ្ហាធំធ្វើឱ្យប៉ះពាល់ដល់ការរស់នៅរបស់គេដែរឬទេ?ហេតុអ្វី?<br>4-តើមកពីហេតុអ្វីទៅបានជាបណ្ដាលឱ្យមានបញ្ហាដូច្នេះ?ចូររៀបរាប់បង្ហាញ ។ | 1-តើមានវិធានការណាខ្លះដែលត្រូវដោះស្រាយបញ្ហាទាំងនេះឱ្យបានប្រសើរឡើង? ចូររៀបរាប់ ។<br>2- បើប៉ូលីសខ្លះ និយាយដូច្នេះ តើពួកគេគិតថាយោបល់នេះយ៉ាងដូចម្ដេចដែរ?ហេតុអ្វីទៅ?<br>3-តើមានច្បាប់ការពារដែរឬទេ? ច្បាប់ណាខ្លះ?មាត្រាណា ?(ពិនិត្យមើលឧបសម្ព័ន្ធ) | 1-តើពួកគេមានសំណូមពរ និងយុទ្ធសាស្ត្រដូចម្ដេចខ្លះដើម្បីស្តារនូវសន្តិសុខរបស់គេឱ្យមានភាពកក់ក្ដៅឡើងវិញនោះ? រកចំណុចជាយុទ្ធសាស្ត្រ :<br>....................................................<br>....................................................<br>2-តើជាអ្នកណាដែលជាកំលាំងជួយជំរុញការបោសសំអាតអំពើទាំងនេះបន្ទាប់ពីសមត្ថកិច្ច? |

# III. ឧបសម្ពន្ធ័លំហាត់

## ១.សេចក្ដីប្រកាសជាសាកលស្ដីអំពីសិទ្ធិមនុស្ស

*មាត្រា១ :* មនុស្សទាំងអស់កើតមកមានសេរីភាព ។មានសេចក្ដីថ្លៃថ្នូរនិងសិទ្ធិស្មើៗគ្នា ។មនុស្សទាំអស់មានវិចារណញ្ញាណនិងសតិសម្បជញ្ញៈដូចៗគ្នា ដូច្នេះត្រូវរាប់អានគ្នាក្នុងស្មារតីភាតរភាពជាបងប្អូន ។

*មាត្រា៣ :* ជនរាល់រូបមានសិទ្ធិរស់នៅ មានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន ។

*មាត្រា៤ :* ការជួញដូរមនុស្សគឺជាអំពើខុសច្បាប់និងទាសកម្មត្រូវតែទប់ស្កាត់រាល់ពេលវេលានិងគ្រប់កាលៈ

ទេសៈទាំងអស់ ។

***មាត្រា៥ :*** គ្មានជនណាម្នាក់ត្រូវគេបង្ខំឱ្យទទួលទារុណកម្មឬការវាយដំច្រំចាក់ណាមួយ ឬទណ្ឌកម្មដែលមានភាពសាហាវយង់ឃ្នងឬធ្វើឱ្យជននោះមានអារម្មណ៍ថាខ្លួនមានឋានៈទាបជាងមនុស្សលោកឯទៀតឡើយ ។

*មាត្រា៨ :* ជនណាម្នាក់ដែលមានសិទ្ធិរបស់ខ្លួនត្រូវគេរំលោភ ជននោះអាចមានសិទ្ធិប្ដឹងតវ៉ាដល់ចៅក្រមដែលមានសមត្ថកិច្ច ឱ្យស្វែងរកយុត្តិធម៌ចំពោះខ្លួនបាន ។

## ២.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

***មាត្រា៣២ :*** *(កថាខណ្ឌ១)*ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

***មាត្រា៣៨ :*** *(កថាខណ្ឌ១-២-៤-៧)*

-ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

-ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

-ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទំងន់លើជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ហាមមិនឱ្យធ្វើឡើយ ។

-ជនជាប់ចោទណាក៏ដោយចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

## ៣.កតិកាសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌

***មាត្រា៩:*** រដ្ឋជាភាគីទាំងឡាយនៃកតិកាសញ្ញានេះ ទទួលស្គាល់ថាមនុស្សគ្រប់គ្នាមានសិទ្ធិដើម្បីមានសន្តិសុខសង្គម រួមទាំងកិច្ចធានាខាងសង្គមកិច្ចផង ។

## ៤.ច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាសម័យអន្តរកាល

***មាត្រា៤១ :*** អំពើបង្ករបួសដោយចេតនា (កថាខណ្ឌ១) ជនណាវាយតប់បណ្ដាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ឬពិការបណ្ដោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្ដន្ទាទោសដាក់គុកពី ១ឆ្នាំទៅ ៥ឆ្នាំ ។

***មាត្រា៣៤ :*** *អំពើប្លន់ (កថាខណ្ឌ១)* ការលួច ធ្វើដោយអំពើហិង្សា មានអាវុធឬឥតអាវុធ បណ្ដាលឬមិនបណ្ដាលឱ្យមានរបួស ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្ដន្ទាទោសដាក់គុកពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

ព្រមព្រៀងគ្នាមួយ ដោយមានសំភារៈនៃហេតុមួយឬច្រើន ដើម្បីនឹងរៀបចំបទឧក្រិដ្ឋកម្ម ឬបទមជ្ឈិមមួយឬច្រើន ប្រឆាំងនឹងមនុស្សឬសម្បត្តិទ្រព្យទាំងឡាយ ត្រូវផ្តន្ទាទោសជាបទឧក្រិដ្ឋ ពី ៣ឆ្នាំ ទៅ ១៥ឆ្នាំ។

*មាត្រា៤៣ : (អំពើចោរកម្ម)* គ្រប់ជនដែលលួចឬប៉ុនប៉ងលួចទ្រព្យសម្បត្តិ របស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយពុំមានស្ថានទម្ងន់ទោស ដូចមានចែងក្នុងមាត្រា៣៤ ត្រូវមានទោសពីបទលួច ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៥ឆ្នាំ។

## ៥.ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ អំពើលក់ដូរ និងអំពើអាជីវកម្មលើមនុស្ស

*មាត្រា៣ :* ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជន ឬនីតិជនមានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោមសន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែងឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកមកលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ។

-បើជនរងគ្រោះជាអនីតិជន អាយុតិចជាង១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១៥ឆ្នាំដល់២០ឆ្នាំ។

-អ្នកសមគំនិត អ្នកលក់ឬអ្នកទទួលទិញ ឬអ្នកទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ។

-ត្រូវចាត់ទុកជាសមគំនិតដែរអ្នកដែលបានផ្តល់ប្រាក់ឬបានផ្តល់មធ្យោបាយផ្សេង១សំរាប់ប្រព្រឹត្តបទល្មើស។

-មធ្យោបាយដឹកជញ្ជូនសំភារៈនិងទ្រព្យសម្បត្តិប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

~~~~ចប់~~~~
~~~~

អ្នករកស៊ីជួញ-លក់ដូរមនុស្សគឺជាឧក្រិដ្ឋជន



# សិទ្ធិឱ្យមានការយកចិត្តទុកដាក់ពីរដ្ឋ និង សង្គម

## I.ឧស្សុនៈសិទ្ធិមនុស្ស :

ទោះជាយ៉ាងណាក៏ដោយ កូនចៅនៅតែស្ថិតនៅក្នុងការជួយគាំពារពីឪពុកម្តាយជានិច្ច ទោះជានៅលីវឬមានគ្រួសារក៏ដោយ ។

មនុស្សទាំងអស់ក្នុងពិភពលោក ត្រូវតែស្ថិតនៅ ក្នុងការគ្រប់គ្រងរបស់រដ្ឋទីទៃៗ រៀងៗខ្លួន ។ភាពមិនគ្រប់មិនគ្រាន់ក្នុងជីវភាពរស់នៅឬក៏បើកភ្នែកឡើងឃើញតែក្រ ចំពោះមនុស្សភាគច្រើនដែលស្ថិតក្នុងសភាពបែបនេះ តែងតែយល់ថា ភាពខ្វះខាត ឬភាពក្រីក្រ របស់ពួកគេ គឺបណ្តាលមកពីព្រហ្មលិខិត ឬកម្មផលពីជាតិមុនសាងមិនល្អ បានជាជាតិនេះវេទនាដូច្នេះ ទោះបីជាពួកគេខំប្រឹងប្រែងបែកញើសហូរញើសយ៉ាងណាក៏ដោយ។ វាជាការពិតណាស់ ចំពោះមនុស្សខ្លះដែលខ្ជិលច្រអូសក្នុងការចិញ្ចឹមជីវិតរបស់ខ្លួន ក៏ប៉ុន្តែវាមិនបានផ្តោតទៅលើចំណុចនេះប៉ុន្មានទេ តែចំណុចជាអាទិភាព គឺវាបណ្តាលមកពី ការរស់នៅដោយខ្វះមធ្យោបាយ ឧបករណ៍ និងសំភារៈផ្សេងៗទៀត......ដែលជាតំរូវការរបស់ពួកគេ ហើយដែលត្រូវតែបានការសហការ ឬការជួយ ឬការគាំពារពីមជ្ឈដ្ឋានដទៃៗទៀត ដែលអាចញ៉ាំងឱ្យ ជីវភាពរបស់ពួកគេ ល្មមរស់នៅបាន ឬក៏និយាយថាមានជីវភាពរស់នៅសមរម្យ ។

★ *តើភាពមិនគ្រប់មិនគ្រាន់ ឬភាពក្រីក្រ វាជាបច្ច័យធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស ក្នុងការរស់នៅដែរឬទេ? ឬអាចនិយាយថា តើជីវភាពរស់នៅខ្វះខាត ឬភាពក្រីក្រ វាជាការរំលោភសិទ្ធិមនុស្ស ដែរឬទេ?*

## II.ករណីសិក្សា :

**ក).** **<u>សិក្សាលំហាត់១</u>** : *បងប្អូនកសិករតែងតែពោលថា* : ស្រូវយើងធ្វើបាន បរិភោគស្ទើរមិនគ្រប់មិនគ្រាន់បើបេះពីមាត់ពី កខ្លះយកទៅលក់តំលៃថោក ។បើទិញឥវ៉ាន់ចិន ហាងឆេងឡើងចុះ ស្រេចលើមាត់គេថា។ កសិករម្នាក់ដកដង្ហើមធំ ហើយនិយាយថា ឥវ៉ាន់គេចេះតែហូរចូល ហើយថ្លៃកប់ពពក ចំនែកឥវ៉ាន់ក្នុងស្រុកជូនផលិតបានហើយ គ្មានច្រកចេញ គ្មានហាងឆេង ដូចជា ពោត ថ្នាំជក់ សណ្តែក ល្ង ។ល ។ ជាក់ស្តែងជាច្រើនឆ្នាំកន្លងទៅនេះ ដូចជាគ្មាននរណាអើពើជួយដោះស្រាយ យើងឡើយ ។ បើនិយាយពីគមនាគមន៍ នៅក្នុងស្រុកភូមិយើងរលុះរលាញ ជូនភ្លៀងដីស្អិតទៅណាមកណាមិនរួច តើការដឹកជញ្ជូន


រោងចក្រ

ធ្វើម៉េចនឹងទាន់ហាងឆេង ដូចគេនៅក្បែរផ្សារ? ទីបញ្ចប់ កសិករនោះនិយាយថា **តើយើងមានអ្វី** គួរឱ្យសង្ឃឹមទៀត ក្នុងជីវភាពរស់នៅរបស់យើង?

### ០ ពិភាក្សា

| សំណួរកេបញ្ហា | សំណួរកេដំណោះស្រាយ | អនុសាសន៍ឬសំណូមពរ |
|---|---|---|
| 1-តើក្រុមកសិករកំពុងតែប្រឈមទៅនឹងអ្វីខ្លះ តាមករណីសិក្សាខាងលើ?<br>- រាប់បញ្ចាក់មូលហេតុទាំងនោះដូចជា :<br>........................................<br>........................................<br>2-តើវាជាការខ្វិលច្រអូសរបស់ក្រុមកសិករទាំងនោះ ដែរឬទេ?<br>3-ចំពោះអំពើប្រឈមមុខទាំងនោះ តើ ពួកគេគិតថាវាជារឿងពិតឬមិនពិត? ហេតុអ្វី?<br>4-តើវាប៉ះពាល់ដល់សិទ្ធិមនុស្សក្នុងការរស់នៅដែរឬទេ?ព្រោះអ្វី? | 1-តើវាមានតែពួកគេប៉ុណ្ណោះឬដែលត្រូវប្រឈមមុខដោះស្រាយនឹងជីវភាពរបស់ពួកគេនោះ?ហេតុអ្វី?<br>2-តើពួកគេ មានសិទ្ធិប្រាប់អ្នកណាខ្លះ ដើម្បី ឱ្យជួយដោះស្រាយក្នុងរឿងនេះ?<br>3-ចូរបង្ហាញពីវិធីដែលធ្វើឱ្យកសិផលរបស់ពួកគេ អាចដោះស្រាយ ជីវភាពបានសមរម្យ?<br>- បង្ហាញពីវិធី<br>:................................<br>........................................<br>4-តើមានច្បាប់ការពារអំពីបញ្ហាទាំងនេះទេ?មានមាត្រា ណាខ្លះ? | - បើបញ្ហាជីវភាពរបស់ពួកគេមិនត្រូវបានដោះស្រាយសមស្រប តើពួកគេមានវិធានឬមានសំណូមពរ ឬមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីឱ្យស្របទៅនឹងការគោរពសិទ្ធិមនុស្សក្នុងការរស់នៅរបស់ពួកគេ?<br>រៀបរាប់ពីយុទ្ធសាស្ត្រ :<br>........................................<br>........................................<br>........................................ |

## ២). សិក្សាលំហាត់ទី២ :

ស្ថិតនៅក្នុងស្រុកនៃខេត្តមួយ មានគ្រួសារមួយបានកាន់កាប់ដីមួយកន្លែងចាប់តាំងពីឆ្នាំពីឆ្នាំ១៩៧៩មក ដែលមានទំហំ១ហិកតារ (ទ: ១០០ម និង ប: ១០០ម)ហើយដីនោះស្ថិតនៅក្នុងតំបន់ខ្មែរក្រហមអុកឡុក។ នៅឆ្នាំ១៩៨៦អាជ្ញាធរបានសាងសង់សាលាស្រុកជាប់នឹងព្រំប្រទល់ដីគ្រួសារនោះ។

នៅឆ្នាំ១៩៨៨ គ្រួសារនោះបានសុំលិខិតកាន់កាប់ តែផ្ទុយទៅវិញអាជ្ញាធរស្រុកបានដកហូតយកដីគ្រួសារនោះអស់កន្លះហិកតារ (ដកយកទទឹង :៥០ម និងបណ្តោយ :១០០ម)ហើយសំរេចថាឱ្យគ្រួសារនោះកាន់កាប់ពាក់កណ្តាលចុះ។

នៅឆ្នាំ១៩៩៨ គ្រួសារនោះ បានសង់លំនៅដ្ឋានលើទំហំដីពាក់កណ្តាលនោះ ហើយព្យាយាមសុំលិខិតកាន់កាប់ តែអាជ្ញាធរស្រុក នៅតែមិនសំរេចឱ្យ ផ្ទុយទៅវិញតំរូវឱ្យគ្រួសារនេះ ប្តូរដីរបស់ខ្លួន ដែលនៅសល់ពីការដក ហូតពីពេលមុន ដែលមានទទឹង៥០ម និង បណ្តោយ ១០០ម នោះ មកជំនួសនឹងដីដែលមានទទឹង៣០មនិង បណ្តោយ៤០មទៅវិញ ។ ចំណែកដីដែលប្តូរនោះ មានទីតាំងនៅក្រោយសាលាស្រុក ។អាជ្ញាធរស្រុកបាន សន្យាថា នឹងធ្វើលិខិតឱ្យគ្រួសារនោះកាន់កាប់ ។

គ្រួសារនោះបានបដិសេធ ហើយនិយាយថា ដីរបស់គេនៅជាប់នឹងផ្លូវជាតិ ឯដីដែលប្តូរនោះនៅកន្លែត ហើយ មានទំហំតូចជាងឆ្ងាយពីដីរបស់គេ ។ប៉ុន្តែនៅពេលថ្មីៗនេះ អាជ្ញាធរស្រុកបានបញ្ជាកងរាជអាវុធហត្ថឱ្យរុះ រោងមួយ មានទទឹង ៣ម និងបណ្តោយ ៤ម របស់គ្រួសារនោះ និងធ្វើការហ៊ុមពទ្ធ័យកដីអស់ទទឹង៣០មនិង បណ្តោយ១០០មទៀត ។នៅទីចុងបំផុត បច្ចុប្បន្នគ្រួសារនេះ នៅសល់ដី តែទទឹង២០ម និងបណ្តោយ១០០ម តែប៉ុណ្ណោះ ។ *(សូមបញ្ជាក់បន្ថែមថា កាលពីដំបូងឡើយ ទំហំដីរបស់គ្រួសារនេះ មានទទឹង ដល់ទៅ១០០ម និង បណ្តោយ ១០០ម)* ។

**•ពិភាក្សា**

| **សំនួរបំផុសបញ្ហា** | **សំនួររកដំណោះស្រាយ** | **អនុសាសន៍ឬសំណូមពរ** |
|---|---|---|
| 1-តាមករណីសិក្សានេះតើជារឿងអ្វី?<br>2-តើការកាន់កាប់ដីធ្លីរបស់គ្រួសារនេះ ចាប់ពីពេលណាមក?<br>3-តើដីនេះពីដំបូងមានទំហំប៉ុន្មាន ហើយ ចុងក្រោយបំផុតមានទំហំប៉ុន្មាន?<br>4-ហេតុអ្វីបានជាដីនេះនៅសល់ទំហំ ប៉ុណ្ណេះ?<br>5-តើបច្ចុប្បន្ននេះវាមានច្រើនទេ រឿង ទំនាស់ដីធ្លី រវាងអាជ្ញាធរនិងប្រជាពល រដ្ឋនោះ?សូមផ្តល់ឧទាហរណ៍ ។ | 1-តើការកាន់កាប់ដីធ្លីរបស់គ្រួសារនេះ គឺជារឿងខុសច្បាប់ឬជារឿងត្រឹមត្រូវ? ហេតុអ្វី?<br>2-តើការដកហូតដីធ្លីរបស់អាជ្ញាធរពីគ្រួ សារនេះគឺជារឿងត្រឹមត្រូវតាមច្បាប់ ឬក៏ខុស?ហេតុអ្វី?<br>3-បើសិនជាការកាន់កាប់ដីរបស់គ្រួសារ នេះមិនត្រឹមត្រូវ គឺជាអំពើអ្វី?<br>4-បើសិនជាការដកហូតប្រព្រឹត្តឡើងមិន ត្រឹមត្រូវដោយអាជ្ញានោះ គឺជាអំពើអ្វី?<br>5-តើនរណា មានតួនាទីដោះស្រាយ?<br>6-តើមានច្បាប់ការពារដីធ្លីទេ?ច្បាប់ណា ហើយមាត្រាណាខ្លះ?(មើលឧបសម្ពន្ធ) | 1-បើអស់លោកអ្នកយល់ថា អាជ្ញាធរ បានរំលោភទៅលើគ្រួសារនេះ ហើយបើ សិនជាអស់លោកអ្នកយល់ដឹងពីផ្លូវច្បាប់ តើពួកលោកគួរប្រាប់គ្រួសារនោះដូច ម្តេច ឬតាមវិធីអ្វីខ្លះ ដើម្បីគ្នាទទួលបាន នូវភាពយុត្តិធម៌នោះ?<br><br>2-បើសិនជារឿងទំនាស់ដីធ្លីដូចគ្រួសារ នេះកើតមានកាន់តែច្រើនឡើងៗឬក៏វា ធ្លាក់ចំលើអស់លោកវិញ តើលោកត្រូវ រៀបចំយុទ្ធសាស្ត្របែបណាខ្លះ ដើម្បី ឆ្លើយតបទៅនឹងអំពើរំលោភទាំងនោះ? |

## III.ខ្លឹមសារច្បាប់សំខាន់ :

### ១.សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស

***មាត្រា១៧*** : ជនរាល់រូបមានសិទ្ធិទទួលកម្មសិទ្ធិ ដែលខ្លួនអាចរក្សាឃុំគ្រងទុកសំរាប់តែម្នាក់ឯងឬចែកចាយទៅឱ្យអ្នកឯទៀតក្តី ហើយគ្មានជនណាម្នាក់អាចយកទ្រព្យសម្បត្តិរបស់អ្នកឡើយ ដោយមិនមានហេតុផលច្បាស់លាស់ ។

***មាត្រា២២*** : ក្នុងឋានៈជាមនុស្សនៅក្នុងពិភពលោកនេះ ជនណាក៏ដោយ មានសិទ្ធទទួលសេចក្តីត្រូវការជាមូលដ្ឋានរបស់ខ្លួន ដែលអាចឱ្យជននោះ រស់នៅបានដោយមានមោទនភាព និងក្លាយទៅបុគ្គលម្នាក់ដែលខ្លួនប៉ងប្រាថ្នា ហើយប្រទេសឯទៀត និងក្រុមប្រទេសឯទៀត ត្រូវតែជួយ ។

***មាត្រា២៥*** : ជនរាល់រូបមានសិទ្ធិទទួលនូវអ្វីដែលខ្លួនត្រូវការ ដើម្បីឱ្យមានជីវភាពរស់នៅសមរម្យល្មម ជារួមមានចំណីអាហារ សំលៀកបំពាក់ លំនៅដ្ឋាននិងការព្យាបាលជំងឺផ្ទាល់ខ្លួននិងគ្រួសារខ្លួន ។

ជនរាល់រូបមានសិទ្ធិទទួលជំនួយពីសង្គម បើសិនជាជននោះមានជំងឺ ឬមិនអាចធ្វើការកើត ឬចាស់ជរា ឬក្លាយទៅជាពោះម៉ាយ ឬមេម៉ាយ ឬនៅក្នុងកាលទេសៈនានាដែលជននោះមិនអាចធ្វើការកើត ។

### ២.ច្បាប់ភូមិបាល :

***មាត្រា១*** ចែងថាៈ រដ្ឋមិនទទួលស្គាល់ដាច់ខាត របបកម្មសិទ្ធិចាស់លើដីធ្លីមុនឆ្នាំ១៩៧៩ ។

***មាត្រា៣*** ចែងថាៈ រដ្ឋធានាឱ្យអ្នកប្រើប្រាស់ដីធ្លី នូវសិទ្ធិកាន់កាប់ និងទទួលផលស្របច្បាប់អំពីដីធ្លី ។ការប៉ះពាល់ដល់កម្មសិទ្ធិឯកជននៃពលរដ្ឋ ត្រូវហាមឃាត់មិនឱ្យមាន វៀរលែងតែប្រយោជន៍សាធារណៈតំរូវឱ្យធ្វើក្នុងករណីដែលមានចែងក្នុងច្បាប់ ។ក្នុងន័យនេះម្ចាស់កម្មសិទ្ធិមានសិទ្ធិទទួលបំណាច់ជាមុនដោយត្រឹមត្រូវនិងសមរម្យ ។

### ៣.ច្បាប់រដ្ឋធម្មនុញ្ញ :

***មាត្រា៦១*** : រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យ កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ។

***មាត្រា៦២*** : *រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។*

***មាត្រា៦៣*** :រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកំរិតសមរម្យ ។

៤.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ :

**មាត្រា១១ :** *(វាក្យខណ្ឌ១-២)*

- រដ្ឋជាភាគីទាំងឡាយទទួលស្គាល់នូវសិទ្ធិរបស់មនុស្សម្នាក់ៗ ក្នុងការមានជីវភាពរស់នៅដ៏សមរម្យសំរាប់ខ្លួនគេផ្ទាល់ និងសំរាប់គ្រួសារគេ រួមទាំងមានចំណីអាហារគ្រប់គ្រាន់ សំលៀកបំពាក់និងទីលំនៅ ព្រមទាំងសំភារៈផ្សេងៗ សំរាប់ធ្វើឱ្យការរស់នៅបានប្រសើរឡើងជាលំដាប់តទៅ ។
- រដ្ឋទាំងឡាយជាភាគី ដែលទទួលស្គាល់នូវសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប ក្នុងការប្រាសចាកពីសេចក្តីស្រេកឃ្លាន ត្រូវចាត់វិធានការនានា (ក្នុងរឿងក្តីនេះ) ដោយឯកឯងផង ដោយរួមសហការជាមួយអន្តរជាតិផង ។

**មាត្រា១២** *(ចំណុចលេខ 1-2 និងចំណុច ក.គនិង ឃ) :*

1-រដ្ឋជាភាគីទាំងឡាយ ទទួលស្គាល់នូវសិទ្ធិមួយដែលចែងថា បុគ្គលគ្រប់រូបរស់នៅមានសិទ្ធិប្រកបដោយសុខុមាលភាពយ៉ាងប្រពៃ ទាំងផ្នែករាងកាយ ទាំងផ្នែកគំនិតនិងប្រាជ្ញា ។

2-ដើម្បីឱ្យបានសំរេចតាមគោលដៅទាំងស្រុងខាងលើនេះ រដ្ឋភាគីទាំងឡាយត្រូវមានវិធានការចាំបាច់ផ្សេងៗដូចជា :

ក).ការយកចិត្តទុកដាក់ទៅលើការបន្ថយនៃចំនួនទារក ដែលស្លាប់ក្នុងពោះ មរណៈភាពនៃកុមារ ហើយនិងការជួយឧបត្ថម្ភឱ្យក្មេងចំរើនវ័យដោយមានសុខភាពល្អ ។

ខ).វិធីការពារ ការព្យាបាល និងការត្រួតពិនិត្យរោគឆ្លង ជំងឺដែលកើតតាមតំបន់ និងជំងឺដែលទាក់ទងជាមួយការងារ ព្រមទាំងជំងឺដំកាត់ដែលមានផ្សេងៗទៀត ។

គ).ការបង្កើតលក្ខខណ្ឌផ្សេងៗ ដើម្បីឱ្យមានកិច្ចបំរុងសុខុមាលភាព និងការព្យាបាលជាចាំបាច់នៅពេលដែលប្រជាពលរដ្ឋមានជំងឺផ្សេងៗ ។

ចប់

## សិទ្ធិមានមុខរបរ









# ប្រជាពលរដ្ឋក្នុងរបបប្រជាធិបតេយ្យ

## I. ឧស្សាហ៍សិទ្ធិមនុស្ស

កន្លងមក ស្ទើរតែគ្រប់ជំនាន់នៃរបបសង្គម មនុស្សបាក់បបខួបខួច បាក់ស្បាត មិនហ៊ានបញ្ចេញវាចា ឬពាក្យខ្មែរថាដាំដើមគរ ឬក៏ពន្យល់គ្នាៗថា " ធ្វើម៉េចឱ្យតែក្រពះឆ្អែតទៅបានហើយ " ប្រយត្ន័ជាប់គុក ច្រវាក់ ឬប្រយត្ន័បាត់ខ្លួន កុំចេះធ្វើដឹងធ្វើឮ ។ល។ នេះហើយគឺជាកេរ្តិ៍បន្សល់ទុកឱ្យមនុស្សតៗគ្នា ទោះជាមនុស្សរស់នៅមានភាពត្រដាបត្រដួស ក្រីក្រយ៉ាងណាក៏ដោយក៏មិនហ៊ានស្រែកឱ្យនរណាឮដែរ យ៉ាងច្រើនហ៊ានបញ្ចេញសម្លេងត្រឹមគ្រួសារឯងប៉ុណ្ណោះ ក៏ប៉ុន្តែពួកគេមិនបានដឹងថា គេមានសិទ្ធិសេរីភាពបែបណា នៅក្នុងឋានៈជាមនុស្សនោះទេ ។

យោងតាមលក្ខខណ្ឌធម្មជាតិដែលកើតមកជាមនុស្ស មនុស្សទាំងអស់មានសេរីភាពក្នុងការបញ្ចេញមតិប្រាប់អ្នកឯទៀតទៅតាមទ្រង់ទ្រាយច្រើនបែបច្រើនយ៉ាង ដូចជាការចូលរួមប្រជុំដោយសន្តិវិធី...មិនគួរមានអ្នកណាម្នាក់ហាមឃាត់ខ្លួនឱ្យនៅស្ងៀមបានឡើយ ។ជាមួយនេះដែរ មនុស្សមានសិទ្ធិចូលរួមជាមួយអ្នកណាដែលខ្លួនចង់ ក៏ប៉ុន្តែមិនមានអ្នកណាអាចបង្ខំយើង ឱ្យចូលរួមជាមួយអ្នកឯទៀត ដោយយើងមិនចង់នោះឡើយ ។

*✸ តើដើម្បីអ្វីទៅ បានជាមនុស្សត្រូវការ សេរីភាពក្នុងការបញ្ចេញមតិយោបល់?*

គឺគ្មានអ្វីក្រៅពី ការបំពេញនូវសេចក្ដីត្រូវការសព្វជំពូករបស់ពួកគេ ដើម្បីជីវភាពរស់នៅឱ្យបានសមរម្យ ក្នុងឋានៈជាមនុស្សនោះឡើយ ។ ដូច្នេះសេរីភាពក្នុងការស្ដាប់ ការផ្ដល់ពត៌មាន ការទទួលពត៌មាន ការបញ្ចេញមតិ ការចូលរួម គឺវាជាច្រកតែមួយសំរាប់ការអភិវឌ្ឍន៍គ្រួសារ ក៏ដូចជាការអភិវឌ្ឍន៍សង្គមជាតិដែរ ។ទន្ទឹមនឹងនេះផងដែរ សេរីភាពក្នុងការបញ្ចេញមតិ វាគឺជាគន្លឹះសំរាប់ដោះស្រាយបញ្ហា បានន័យថា មនុស្សម្នាក់ៗមិនគួរទ្រាំតាមកម្មទេ ត្រូវតែស្រែកឱ្យគេឮ ឬក៏សំដែងប្រាប់នរណាម្នាក់ ឬច្រើននាក់ ដើម្បីឱ្យគេជួយយើង ។ ផ្ទុយទៅវិញបើសិនជាមានការធ្វើទុក្ខបុកម្នេញ ទៅលើសេរីភាពក្នុងការសំដែងមតិយោបល់ គឺវាជាការរំលោភសិទ្ធិមនុស្សពេញទី ប្រឆាំងនឹងច្បាប់ធម្មជាតិនៃមនុស្ស ក៏ដូចជាច្បាប់របស់ប្រទេសដែរ ។ ម្យ៉ាងវិញទៀត មនុស្សមិនត្រូវបានគេបណ្ដោយតាមព្រេងវាសនា ឬរស់នៅដោយឯកោនោះឡើយ គឺត្រូវមានទំនាក់ទំនងទៅនឹងអ្នកដទៃ ជាពិសេសរដ្ឋ និង សង្គម ទើបអាចរស់បានក្នុងន័យ ភាតរភាពជាបងប្អូន ។

យើងទាំងអស់គ្នាអាចចូលរួមសំរេចកិច្ចការអ្វីៗ នៅគ្រប់កាលៈទេសៈ នៅគ្រប់តំណាក់ការ ដែលទាក់ទងទៅនឹងជីវភាពរបស់ខ្លួន ជាពិសេសមនុស្សទាំងអស់ មានអំណាចគ្រប់គ្រងប្រទេស *ដូច្នេះតំណាងរបស់គេដែល*


ការគោរពសិទ្ធិមនុស្សគឺជាការគោរពច្បាប់

*បានជ្រើសតាំង ដោយការបោះឆ្នោតនោះ គឺគ្រាន់តែជាអ្នកបំរើផលប្រយោជន៍.ឱ្យពួកគេតែប៉ុណ្ណោះ ។*




## II.ករណីសិក្សា

ក្នុងឆ្នាំ ១៩៩៧ ប្រហែលជាម៉ោង ៨.០០យប់ មានការជួបជុំ ស៊ីផឹកសប្បាយ *(ស្របនឹងពិធីបុណ្យភ្ជុំបិណ្ឌ)* នៅក្នុងរបងផ្ទះសកម្មជនគណបក្សមួយ ។ពេលនោះមានកងជីវពលឃុំម្នាក់ បានមកអើតក្រៅរបងផ្ទះនោះ ។ ប្រពន្ធម្ចាស់ផ្ទះ បានឃើញក៏អញ្ជើញជីវពលនោះឱ្យចូលរួមក្នុងការជួបជុំនោះ តែគាត់បដិសេធហើយនិយាយថា " ពួកនេះផឹកស៊ីដូចឆ្កែ" ប្រពន្ធម្ចាស់ផ្ទះបានអង្វរក ការមាត់ឡូឡាក្រុមប្តីគាត់ហើយកងជីវពលនោះក៏ចេញទៅ ។ ប្រហែល ៤-៥ នាទីក្រោយមក កងជីវពលនោះត្រលប់មកវិញដោយមានកាំភ្លើង អាកា៤៧មួយដើមមកជាមួយ ហើយបាញ់រះទៅលើក្រុមផឹកស៊ីនោះភ្លាម ព្រមទាំបោកគ្រាប់បែកផងដែរ ។ជនរងគ្រោះបានស្លាប់អស់ ៥នាក់ ដោយស្នាដៃកងជីវពលឃុំនោះ *( មានគេផ្តល់ពត៌មានទៅអាជ្ញាធរឃុំភ្លាមក្នុងពេលនោះ)* ។ ទោះបីសាក្សីបានផ្តល់ឈ្មោះជនល្មើសទៅអាជ្ញាធរនិងប៉ូលីសក៏ដោយ ក៏ជនល្មើសបានស្នាក់នៅក្នុងផ្ទះរបស់គេរយៈពេលពីរថ្ងៃបន្ទាប់ពីការសំលាប់រង្គាល ដោយពុំមានអ្វីកើតឡើងចំពោះរូបគេទេ ។ ក្រោយមកជនល្មើសបានគេចខ្លួនបាត់ទៅ ។ តាមការអះអាងរបស់ប៉ូលីស និងមន្ត្រីតុលាការថា ពួកគេបានខិតខំស្វែងរកជនល្មើសខ្លាំងណាស់ដែរ តែរហូតមកដល់ពេលនេះមិនទាន់ចាប់បាននៅឡើយ ។

*** សំនួរពិភាក្សា**

| សំនួរបំផុសបញ្ហា | សំណួរគេដំណោះស្រាយ | យុទ្ធសាស្ត្រការពារនិងសំណូមពរ |
|---|---|---|
| 1-តើមកពីហេតុអ្វី បានជាកងជីវពល បាញ់សំលាប់ទៅលើក្រុមនោះ?<br>2-តើក្រុមនោះមានកំហុសអ្វីខ្លះ? ហេតុអ្វី?<br>3-តើក្រុមនោះត្រូវមានទោសឬទេ? ហេតុអ្វី?<br>4-បើសិនជាជនរងគ្រោះ ត្រូវបានគេចោទថា ឃុបឃិតចូលរួមជាមួយគណៈបក្សនយោបាយ ផ្ទុយពីកងជីវពលនោះ តើពួកគេមានទោសកំរិតណា?ហេតុអ្វី?<br>5-តើកងជីវពលនោះមានទោសឬទេ? បើមានទោស កំរិត(ថ្នាក់)ណា? | 1-តើកងជីវពលនោះ ត្រូវបានគេគិតដូចម្តេច?អ្នកណាមានតួនាទីក្នុងរឿងនេះ?<br>2-តាមករណីសិក្សាខាងលើបាននិយាយថា ប៉ូលីសនិងតុលាការខិតខំតាមចាប់ជនល្មើសយ៉ាងខ្លាំង តើពិតឬមិនពិត? ហេតុអ្វី?<br>3-បើសិនជាចាប់កងជីវពលនេះមិនបាន តើវាជាកំហុសរបស់ប៉ូលីសនិងតុលាការដែរឬទេ?ហេតុអ្វី?<br>4-តើមានច្បាប់ការពារ ទាក់ទងក្នុងរឿងនេះឬទេ?មាត្រាណាខ្លះ? | 1-អ្នកចូលរួមគួរមានយុទ្ធសាស្ត្របែបណា ឬសំណូមពរបែបណា ចំពោះឧក្រិដ្ឋជនដូចជាកងជីវពលនេះ :<br>ក-វិធានការរបស់ពួកគេផ្ទាល់?<br>ខ-តើសំណូមពរទៅនគរបាលដូចម្តេច?<br>គ-តើសំណូមពរទៅតុលាការដូចម្តេច?<br>2-តើអស់លោក លោកស្រី មានបានដឹងថា ឧក្រិដ្ឋជនដែលមិនទាន់ចាប់បាន( *អាចមានន័យប្រហែលនឹងរួចខ្លួនដោយមិនទាន់កាត់ទោស*) តើមានច្រើនទេ?ហេតុអ្វី? |

## III.សិក្សាលំហាត់

សព្វថ្ងៃ ប្រទេសយើងអនុវត្តរបបប្រជាធិបតេយ្យសេរី បានន័យថា ប្រជាពលរដ្ឋជាម្ចាស់អំណាច ។ ឧបមាថាឥឡូវនេះ ឃុំរបស់លោកអ្នក រដ្ឋាភិបាលតម្រូវឱ្យជ្រើសរើសមេឃុំថ្មី ដោយយល់ឃើញថាមេឃុំចាស់ មិនបំរើផលប្រយោជន៍ឱ្យអស់លោកអ្នក ។ មានបេក្ខជន ៣ នាក់ ត្រៀមឈរធ្វើមេឃុំ ។ តាមការសង្កេតបុគ្គលិកលក្ខណៈ បេក្ខជនមេឃុំទាំង៣ ឃើញថា :

-បេក្ខជនមេឃុំទី១ : *ជាអ្នកធ្លាប់បួសរៀន ចំណេះដឹងមធ្យម និងមានចរិតសមរម្យ.*

-បេក្ខជនមេឃុំទី២ : *ជាអ្នកមានទ្រព្យសម្បត្តិ តែខ្វះការចេះដឹង តាមពត៌មានឮថា គាត់បំរុងចែកលុយមួយគ្រួសារ ២០ដុល្លារ ហើយនិងមានសំភារៈមួយចំនួនទៀត ។*

-បេក្ខជនមេឃុំទី៣ : *ជាអ្នកមានការចេះដឹងល្អ ឆ្លាតវាងវៃ តែចរិតលក្ខណៈបែបច្រងេងច្រងាង ។*

*សំនួរ : -តើអ្នកចូលរួម ជ្រើសរើសបេក្ខជនមួយណា ក្នុងចំណោមអ្នកទាំងបីខាងលើ?*

*ហេតុអ្វីបានជា លោកអ្នក ស្រលាញ់បេក្ខជនរូបនោះ?ហេតុផល ។ ចូរបន្ថែមអនុសាសន៍ ចំពោះអ្នកដឹកនាំល្អ ។*

## IV.ឧបសម្ព័ន្ធលំហាត់

### ១.សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស

**មាត្រា១៨ :** ជនរាល់រូបមានជំនឿជឿទៅលើអ្វីមួយដែលខ្លួនចង់ជឿ អាចនឹងមានគំនិតអំពីអ្វីដែលខុសនិងត្រូវ និងអាចមានជំនឿទៅលើសាសនាណាមួយដែលខ្លួនចង់ ហើយជននោះអាចដូរសាសនារបស់ខ្លួនបានបើសិនជាខ្លួនចង់ ដោយមិនមានការជ្រៀតជ្រែកណាមួយឡើយ ។

**មាត្រា១៩ :**ជនរាល់រូបមានសិទ្ធិបញ្ចេញមតិរបស់ខ្លួនប្រាប់អ្នកឯទៀត ដោយមិនមានជនណាម្នាក់ទៀតអាចហាមឃាត់ខ្លួនឱ្យនៅស្ងៀមបានឡើយ ។ ជននោះអាចអានសារពត៌មាន ឬស្តាប់វិទ្យុ ហើយក៏មានសិទ្ធិបោះពុម្ពផ្សាយមតិរបស់ខ្លួន និងផ្សព្វផ្សាយមតិនៅគ្រប់ទិសទីទាំងអស់ ដោយមិនមានជនណាម្នាក់អាចព្យាយាមបញ្ឈប់ខ្លួនបានឡើយ ។

**មាត្រា២០ :**ជនរាល់រូប មានសិទ្ធិចូលរួមដោយសន្តិវិធីជាមួយនឹងអ្នកឯទៀត និងមានសិទ្ធិស្ថិតនៅជាមួយអ្នកណាម្នាក់ដែលខ្លួនចង់ ក៏ប៉ុន្តែមិនមានអ្នកណាម្នាក់អាច បង្ខំឱ្យចូលរួម ឬស្ថិតនៅក្នុងក្រុមណាមួយបានឡើយ ។

**មាត្រា២១ :** ជនរាល់រូបមានសិទ្ធិកាន់កាប់តំណែងសាធារណៈ តាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ដែលសន្លឹកឆ្នោតមួយសម្លេងមានតម្លៃស្មើគ្នា ហើយដែលការបោះឆ្នោតរបស់ជននោះ គឺជាកិច្ចការផ្ទាល់របស់ខ្លួន ។ ដោយសារពលរដ្ឋជាអ្នកបោះឆ្នោតឱ្យ ដូច្នេះរដ្ឋាភិបាលត្រូវធ្វើនូវអ្វី ដែលពលរដ្ឋចង់ឱ្យរដ្ឋាភិបាលធ្វើ ។

### ២.ច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៣២ :**ជនរាល់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា៣៤ :** (ក.៥១) ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

**មាត្រា៣៥ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួម យ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយ របស់ប្រជាពលរដ្ឋ ត្រូវទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា៤១ :** ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា៤២ :** ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

## ៣.ច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជាសម័យអន្តរកាល

**មាត្រា២៨** (បទល្មើសក្នុងការសំដែងមតិ)

-គ្មានជនណាម្នាក់ ត្រូវគេរំខានយាយីរឿងមតិនយោបាយ ជំនឿសាសនា និងពីការដែលខ្លួនជាប់ពូជសាសន៍ជាតិពន្ធណាមួយឡើយ ។

-ច្បាប់ព្រហ្មទណ្ឌដែលមានជាធរមាននៅសព្វថ្ងៃ ទូទាំងប្រទេសកម្ពុជា មិនអាចយកមកសំអាងលើបទល្មើសក្នុងការសំដែងមតិនយោបាយ ឬបទល្មើស មនោគមវិជ្ជាទៀតឡើយ ហើយត្រូវទុកជានិរាករណ៍ ។

**មាត្រា១៨ :** (បទល្មើសជាក់ស្តែង) នគរបាលអាចចាប់ខ្លួនជនណា ដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែងគឺថា:

-បើជនសង្ស័យត្រូវគេឃើញទាន់ ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញ ប្រជាប់ចាប់ប្រកីង ។

-បើជនសង្ស័យត្រូវបានសាក្សី ឬអ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបទល្មើស

ថាជាពិរុទ្ធិជន ។

-បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើស ។

**មាត្រា៣២** : ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនា ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោស ដាក់ជាបទឧក្រិដ្ឋ ពី ៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

## ៤. ច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋកម្ពុជា

**មាត្រា៤៨** : ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតំកល់ទុក ឥតចាត់ការនូវរឿងអាជ្ញា ដែលខ្លួនបានទទួល ទោះមានការសំរុះសំរួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុបញ្ជូនទៅរដ្ឋអាជ្ញា មានសមត្ថកិច្ចជាដរាប ។

"""""""""" **ចប់** """"""""""""



# សិទ្ធិបុគ្គល/ឯកជនរបស់ប្រជាពលរដ្ឋ

## I.ឧស្សាហ៍ៈសិទ្ធិមនុស្ស

អ្វីដែលមនុស្សពេញចិត្តជាងគេ ស្រលាញ់ជាងគេ ហើយដែលអាចជួយជីវភាពរស់នៅ របស់ពួកគេ ឱ្យមានជីវភាពសមរម្យបាននោះ គឺគ្មានអ្វីក្រៅពីការរស់នៅ ដោយមានសិទ្ធិសេរីភាពនោះឡើយ ហើយចំណុចនេះវាជាកត្តាមូលដ្ឋាន និងជាកត្តាសំខាន់ សំរាប់ជួយឱ្យមនុស្សរស់នៅបាន តាមចំណង់ចំនូលចិត្ត ដែលពួកគេអាចធ្វើទៅតាមការសំរេចចិត្តរបស់ពួកគេផ្ទាល់។

ការរស់នៅ ដោយមិនបានគោរព នូវសេចក្ដីសុខរបស់អ្នកដទៃ ឬមិនបានគោរព សិទ្ធិជាឯកជន របស់អ្នកដទៃ ដោយអាងអំណាច សក្ដិយស អាងទ្រព្យសម្បត្តិ ប្រាកដជាឈានទៅរកជំលោះ និងនាំមកនូវ ការរំលោភសិទ្ធិមនុស្ស ដែលមិនអាចជៀសវាងបានឡើយ។

ចំពោះពាក្យថា "*សិទ្ធិបុគ្គល/ឯកជនរបស់ប្រជាពលរដ្ឋ*" មានន័យថា បុគ្គលគ្រប់រូប មានសិទ្ធិការពារខ្លួន កុំឱ្យមានការវាយប្រហារ ទៅលើកិត្តិយស កិត្តិនាមខ្លួន តាមតែអំពើចិត្ត ឬដោយប្រាសចាកពីគន្លងច្បាប់ ឬមានន័យថា គ្មានបុគ្គលណាម្នាក់ ត្រូវបានគេសម្លុត បំភ័យស្មារតី ឬគំរាមកំហែងដោយបង្ខំ ឬប្រើវិធីលួងលោម ឬ ល្បិចបោកបញ្ឆោត ដើម្បីបំណងអ្វីមួយ។ល។ម៉្យាងវិញទៀត គ្មានអ្នកណា មានសិទ្ធិដេញដោលសួររឿងផ្ទាល់ខ្លួនរបស់យើងឬជាបំណងរបស់យើង គ្រួសាររបស់យើង ឬជាអាថ៌កំបាំងនៃការឆ្លើយឆ្លងរបស់យើង ឬចេញចូលលំនៅដ្ឋានរបស់យើង ដោយគ្មានការអនុញ្ញាត ទោះជាអ្នកនោះមានឋានៈអ្វីក៏ដោយ។

យើងអាចដើរហើរឆ្ងាយជិត ឬក៏តាំងទីលំនៅ នៅក្នុងព្រំដែននៃរដ្ឋមួយ ឬចេញក្រៅប្រទេស ឬអាចត្រលប់មកវិញនៅពេលដែលខ្លួនចង់។នៅក្នុងកាលៈទេសៈណាមួយ ដែលយើងយល់ឃើញថា នៅក្នុងស្រុកមានកើតអំពើព្រៃផ្សៃ មានអំពើផ្ដាច់ការ មានចំបាំងរាំងជល មានឃាយីជីវិតមនុស្សនិងកើតឧក្រិដ្ឋអត់ឃ្លាន។ល។ យើងមានសិទ្ធិសុំជ្រកកោននៅប្រទេសក្រៅបាន ដោយគ្មានការហាមឃាត់ឡើយ លើកលែងតែយើងប្រព្រឹត្ត បទឧក្រិដ្ឋអ្វីមួយនោះ ច្បាប់មិនអាចអនុញ្ញាត ឱ្យយើងបានឡើយ។

## II.សំនួរពិភាក្សា

១. បើសិនជាគេ ចង់ចូលផ្ទះលោកអ្នក ដើម្បីឆែកឆេរ ចូរបង្ហាញពីវិធីត្រឹមត្រូវ និងវិធីមិនត្រឹមត្រូវ?

២. បើសិនជាគេចង់ ចាប់លោកអ្នក ចូរបង្ហាញពីវិធីត្រឹមត្រូវ និងវិធីមិនត្រឹមត្រូវ?

៣. បើសិនជាគេ ចង់ដកហូតផ្ទះសំបែង របស់លោកអ្នក ចូរបង្ហាញពីវិធីត្រឹមត្រូវ និងវិធីមិនត្រឹមត្រូវ?

៤. ក). បើសិនជាមានគេតាមដានលោកអ្នកពីរឿងអ្វីមួយ តើគេអាចធ្វើរបៀបនេះបាន ក្នុងករណីណា? ចុះការតាមដានបែបណាដែលមិនត្រូវឱ្យមាន? ចូរបញ្ជាក់ជាឧទាហរណ៍។

ខ).បើសិនជាមានការសម្លាប់មនុស្ស ឬធ្វើទុក្ខបុកម្នេញ សម្លុត គំរាមកំហែង ដោយផ្ទាល់ ឬដោយប្រយោល ទៅលើជនណាដែលមិនដើរតាមបញ្ជា តើទង្វើខាងលើនេះ ពេលណាត្រូវច្បាប់ និងពេលណាមិនត្រូវច្បាប់? ហេតុអ្វី?ហើយអាចចាត់ទុកជាការជ្រៀតជ្រែកដែរឬទេ?

## III.ករណីសិក្សា

ប្រហែលជាម៉ោង ៨.០០យប់ នគរបាលកំពុងដេញចាប់មនុស្សម្នាក់ ដែលគេសង្ស័យថាជាចោរប្លន់ ។ជននោះបានគេចខ្លួនបាត់ ហើយនគរបាលសង្ស័យថាជននោះកំពុងសម្ងំក្នុងផ្ទះមួយ ។ នគរបាលបាន សុំម្ចាស់ផ្ទះដើម្បីឆែកឆេររកជននោះ តែគេបានប្រាប់នគរបាលថា ខ្ញុំមិនបានឃើញអ្វីប្លែកក្នុងផ្ទះខ្ញុំទេ ហើយក៏បដិសេធនឹងការសុំរបស់នគរបាល តែនគរបាលព្យាយាមសំរុកចូល ហើយនិយាយបែបគំរាមទៅម្ចាស់ផ្ទះថា អ្នកឯងការពារជនល្មើស ប្រយត្ន័! ។

**✱ សំនួរពិភាក្សា :**

*១.តើការបដិសេធ របស់ម្ចាស់ផ្ទះ ត្រឹមត្រូវ ឬ មិនត្រឹមត្រូវ? ត្រឹមត្រូវ ហេតុអ្វី? មិនត្រឹមត្រូវ ហេតុអ្វី?*

*២.បើសិនជាប៉ូលីសចូលទៅចាប់ ដោយខ្លាចជននោះរត់គេចខ្លួន តើបានឬមិនបាន? បាន ហេតុអ្វី?មិនបានហេតុអ្វី?*

*៣.តើម្ចាស់ផ្ទះមានសិទ្ធិប្តឹងប៉ូលីសបានទេ បើសិនជាប៉ូលីសសំរុកចូលផ្ទះគេ ដោយមិនបានអនុញ្ញាត?ហេតុអ្វី?*

*៤.តើប៉ូលីសអាចចាប់ ម្ចាស់ផ្ទះនោះបានទេក្នុងពេលនោះ បើគេរឹងទទឹង ដោយចោទថា សមគំនិតជាមួយចោរ? ហេតុអ្វី?*

## IV.ឧបសម្ព័ន្ធសំខាន់

### ១.សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស

*មាត្រា១២* :គ្មានជនណាម្នាក់ ត្រូវគេជ្រៀតជ្រែកក្នុងភាពជាឯកជន គ្រួសារ លំនៅដ្ឋាន ឬបរិហារទៅលើសេចក្តីសុចរិត និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន ដោយមិនមានហេតុផលច្បាស់លាស់ឡើយ។

-បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើស។

*មាត្រា១៩* (ក.ថ.ខណ្ឌ១-២-៣) *(ការចាប់ខ្លួនដោយសំអាងលើភស្តុតាងជាក់ស្តែងយ៉ាងធ្ងន់)*

1-ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបាន លុះត្រាតែមានភស្តុតាងជាក់ស្តែងយ៉ាងខ្លាំង ច្បាស់លាស់ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញឱ្យឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមពិតប្រាកដមែន។

*2-បើជនសង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញាឬចៅក្រម ដែលនឹងត្រូវអនុវត្តដោយ នគរបាលតុលាការ។*

3-ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយដែលនាំឱ្យមានការចាប់ខ្លួនជនជាប់សង្ស័យនោះ។

*មាត្រា២០* :(ការឆែកឆេរក្នុងផ្ទះ)

១.ក្នុងករណីបទល្មើសជាក់ស្តែង នគរបាលអាចធ្វើការឆែកឆេរ។

២.ការឆែកឆេរទាំងនេះ ត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យនិងសាក្សីពីរនាក់ ហើយបើអាចធ្វើបាន សាក្សីគួរយកអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ។

៣.បើមិនមែនជាបទល្មើសគេទាន់ជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមានសេចក្តីអនុញ្ញាតអំពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬពីរដ្ឋអាជ្ញា។ ការឆែកឆេរអាចធ្វើបានតែក្នុងចន្លោះម៉ោង ៦ព្រឹក ទៅ ម៉ោង ៦ល្ងាច។ហើយបើអាចធ្វើបាន ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងចំពោះមុខសាក្សីពីរនាក់ ដែលជ្រើសរើសពីក្នុងចំណោមសមាជិកគ្រួសាររបស់ជនជាប់សង្ស័យ។ភស្តុតាងទាំងឡាយណាដែលបានមកដោយរំលោភនឹងមាត្រានេះ មិនអាចយកជាការបានឡើយក្នុងពិធីកាត់សេចក្តី។

*មាត្រា៥៧* :គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាលនិងឃុំឃាំង ដែលរំលោភដោយមិនរួញរា ទៅលើសិទ្ធិបូរណភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

>>>>>**ចប់**<<<<<


សូមលោកជួយ
អស់ហើយ!



# ស្ត្រី និង ការអភិវឌ្ឍន៍

ៜៜៜៜៜៜៜ

## I. ទស្សនៈសិទ្ធិមនុស្ស

បញ្ហាស្នូលមួយរបស់សង្គម ដែលទាក់ទិនទៅនឹងការមិនទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្សនោះ គឺជាការប្រកាន់វណ្ណៈ ។បញ្ហានោះគឺផ្តោតសំខាន់ទៅលើការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលមនុស្សភាគច្រើនមិនបានគិតថាបញ្ហានោះ ជាទំរង់នៃការរើសអើងទៅតាមក្បួនខ្នាត នៅក្នុងសង្គមមនុស្សនោះទេ ។

អត្ថន័យនៃការរើសអើង គឺជាការផ្តល់កំណើតដល់អំពើកេងប្រវ័ញ្ច និងការជិះជាន់សង្កត់សង្កិនទៅលើអ្នកដទៃ ជាពិសេសស្ត្រីភេទ ដែលសង្គមមនុស្សតែងតែយល់ថា ស្ត្រីមានភាពទន់ខ្សោយមិនអាចធ្វើអ្វីឬគិតអ្វីបានប្រសើរឡើយ ឬយល់ថាមិនបាច់ឱ្យដើរចេញទៅណាមកណា នាំឱ្យតែមានការលំបាកកាយ-ចិត្តឬលំបាកក្នុងការគ្រប់គ្រងនោះទេ ។ នេះហើយគឺជាទស្សនៈដែលគ្របដណ្តប់ ក្នុងសង្គមជាតិទាំងមូល ។

សារៈសំខាន់មួយទៀតនៃការរើសអើង គឺជាស្ពានចំលងដោយស្វ័យប្រវត្តិ ទៅរកអំពើរំលោភបំពានលើស្ត្រីឬអំពើហិង្សាទៅលើស្ត្រីភេទដូចជាសត្វធាតុដោយចាត់ទុកថាអំពើទាំងអស់នេះគឺជារឿងធម្មតារបស់មនុស្សប្រុសនិងស្រី ឬរវាងប្តីនិងប្រពន្ធ ។ល ។

ទស្សនៈសិទ្ធិមនុស្ស និងទស្សនៈថ្មី ហៅថា "***យេនឌ័រ***" បានបង្ហាញថា មនុស្សគួរតែពិចារណាឡើងវិញឱ្យបានល្អិតល្អន់ ឬក៏តាំងផ្តើមសំនួរថា *តើនារីជាមនុស្សឬទេ? តើនារីអាចធ្វើការអភិវឌ្ឍន៍ ត្រូសារដូចបុរសបានដែរឬទេ? និយាយដោយខ្លីថា បើបុរសជាមនុស្ស ស្ត្រីក៏ជាមនុស្សដូចតែគ្នា ។*

ស្ថិតនៅក្នុងតំណាក់ការនេះ គឺជារយៈពេល ឬជាឱកាសមួយ ដែលសង្គមមនុស្ស ជាពិសេសនារីត្រូវតែបើកទស្សនៈថ្មីនិងដ៏អង់អាច ត្រូវតែមានជំនឿទុកចិត្តលើខ្លួនឯង និងគួរកែលំអនូវ ប្រពៃណីណាដែលមិនល្អបែបជាការដាក់ទំងន់មកលើស្ត្រីភេទ ។ល ។ ម្យ៉ាងវិញទៀត ដើម្បីកែប្រែនូវស្ថានភាពនេះបាន ឬក៏កែប្រែក្តីស្រមៃឱ្យក្លាយជាការពិតនោះ លុះត្រាតែនារីរាល់រូប ក្លាយទៅជាភ្នាក់ងារសំរាប់ឱ្យមានការកែប្រែនៅក្នុងសង្គម និងធ្វើការងារទាំងអស់គ្នា ដើម្បីបំបែកនូវការដាក់សំពៀតពីសង្គម ស្តីពីការជិះជាន់សង្កត់សង្កិន រវាងភេទមួយទៅលើភេទមួយទៀត និងដើម្បីចាត់វិធានការបំបាត់ចោលនូវអំពើហិង្សា ក៏ដូចជាការរើសអើងគ្រប់ប្រភេទប្រឆាំងស្ត្រី និងធ្វើយ៉ាងឱ្យសង្គមទទួលស្គាល់ថា ***"សិទ្ធិស្ត្រីគឺជាសិទ្ធិមនុស្ស និងសិទ្ធិស្ត្រីស្មើនឹងសិទ្ធិបុរស"*** ។

***ជាពិសេសប្រែក្លាយសង្គមជាតិទាំងមូល ឱ្យនារីមានការចូលរួមការងារកាន់តែច្រើនឡើងៗ ឬប្រែក្លាយជាគូ***


ពន្ធនាគារ

*នាទីដឹកនាំមានចំនួនប្រហាក់ប្រហែលនឹងបុរស ឬស្មើគ្នាតាមដែលអាចធ្វើទៅបាន ទោះជាត្រូវប្រើរយៈពេលយ៉ាងណាក៏ដោយ។នេះហើយជាទស្សនៈថ្មីហៅថា* **ទស្សនៈយេនឌ័រ** *រវាងបុរសនិងស្ត្រីនៅក្នុងសង្គមមនុស្ស ។*

## II.លំហាត់ពិភាក្សា

១.ភាពខុសគ្នារវាងបុរសនិងស្ត្រី

២.តើលក្ខណាខ្លះ ដែលមិនអាច កែប្រែបាន?ហេតុអ្វី?

៣.តើលក្ខណៈណាខ្លះ ដែលអាច កែប្រែបាន?ហេតុអ្វី?

៤.រៀបរាប់មុខការ របស់បុរសមានអ្វីខ្លះ?

៥.ហេតុអ្វីបានជាបុរស ត្រូវធ្វើកិច្ចការទាំងអស់នេះ?

៦.រៀបរាប់មុខការរបស់ស្ត្រី មានកិច្ចការអ្វីខ្លះ?

៧.ហេតុអ្វី បានជាស្ត្រីត្រូវធ្វើកិច្ចការទាំងអស់នេះ?

៨.តើវាអាចផ្លាស់ប្តូរគ្នាបានទេ រវាងកិច្ចការបុរស ហើយនិងកិច្ចការនារីនោះ?ហេតុអ្វីបានជាផ្លាស់ប្តូរបាន? ហេតុអ្វីបានជា ផ្លាស់ប្តូរមិនបាន?

៩.តើនារីអាចរកប្រាក់ចំណូលសំរាប់ការអភិវឌ្ឍន៍គ្រួសារបានដែរឬទេ?បាន ហេតុអ្វី?មិនបាន ហេតុអ្វី?

១០.ក្នុងការដឹកនាំ នារីសំខាន់ជាង ឬបុរសសំខាន់ជាង?ហេតុអ្វី?

១១.តើសព្វថ្ងៃសម្បូរស្ត្រីជាអ្នកដឹកនាំទេ?ក្នុងគ្រួសារ ក្នុងរដ្ឋ ក្នុងសង្គម?ប្រហែលប៉ុន្មានភាគរយក្នុងផ្នែកនិមួយ១នោះ?

១២.តើមកពីហេតុអ្វីបានជាមិនសូវមានតួនាទីស្ត្រីជាអ្នកដឹកនាំ?

១៣.តើគួរមានវិធានការដូចម្តេចខ្លះ ដើម្បីឱ្យស្ត្រីចូលរួមកិច្ចការក្នុងរដ្ឋឬសង្គមឱ្យបានកាន់តែច្រើននោះ?

១៤.តើមានវិធីអ្វីខ្លះឬរៀបចំយុទ្ធសាស្ត្របែបណាដើម្បីឱ្យស្ត្រីមានតួនាទីដឹកនាំឱ្យកាន់តែច្រើន?

១៥. តើ យេនឌ័រមានន័យដូចម្តេច?

## III.ឧបសម្ព័ន្ធលំហាត់

### ១.ការយល់ដឹងអំពី យេនឌ័រ

១ក) អ្វីទៅហៅថាភេទ?

- សំដៅលើភាពខុសគ្នាផ្នែកជីវសាស្ត្រ( លក្ខខណ្ឌធម្មជាតិ- មេជីវិតរវាងប្តីនិងប្រពន្ធ) ។

ឧទាហរណ៍ សំដៅផ្លូវភេទខុសគ្នារវាងបុរសនិងស្ត្រី មិនអាចផ្លាស់ប្តូរបានឡើយ ។

២ក) អ្វីទៅហៅថា យេនឌ័រ?

គឺសំដៅទៅលើភាពខុសគ្នាក្នុងសង្គមរវាងបុរសនិងស្ត្រីហើយដែលគេបានស្គាល់ដោយខ្លួនឯង ក៏ប៉ុន្តែវាអាចប្រែប្រួលពីពេលមួយទៅពេលមួយទៀត ។យេនឌ័រអាចមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរសនិងស្ត្រីទៅតាមវប្បធម៌នៅក្នុងសង្គម និងរវាងវប្បធម៌មួយទៅវប្បធម៌មួយទៀត ។ **យេនឌ័រ** គឺជាគោលគំនិតផ្នែក **សេដ្ឋកិច្ចសង្គម** ក្នុងការវិភាគលើតួនាទី ទំនួលខុសត្រូវ ឧបសគ្គ ឱកាស និងតំរូវការ របស់បុរសនិងស្ត្រីនៅគ្រប់បរិបទទាំងអស់ ។

ទស្សនៈ យេនឌ័របង្ហាញថា អ្វីដែលធ្វើឱ្យមានភាពខុសគ្នារវាងបុរសនិងស្ត្រីដែលបង្កើតឡើងដោយសង្គម វាក៏អាចមានបំរែបំរួល ដ៏ទូលំទូលាយនៅក្នុងបរិបទសង្គម រវាងបុរសនិងស្ត្រីវិញដែរ និងជាពិសេសរវាងវប្បធម៌មួយទៅវប្បធម៌មួយទៀត ដូចជា មានការបែងចែក ពលកម្ម/ការងារបុរសនិងស្ត្រី ភាពខុសគ្នារវាងបុរសនិងស្ត្រីនៅក្នុងសង្គម ស្ថាប័នច្បាប់ឬសេដ្ឋកិច្ចនិងការទទួលបាននូវធនធាន ។ល ។លើកលែងតែកត្តាជីវសាស្ត្រដែលសំដៅទៅលើភេទជាមូលដ្ឋាន និងមិនអាចប្រែប្រួលបានឡើយ ។

៣ក) ហេតុអ្វីបានជាត្រូវឱ្យមាន យេនឌ័រ?

ការផ្តល់នូវឱកាសស្មើគ្នា និងការកំនត់ទុកនូវអំណាចនិងធនធាន ប្រកបដោយសមធម៌រវាងបុរសនិងស្ត្រីដោយយោងទៅតាមតំរូវការ និងទទួលផលប្រយោជន៍ពីការផ្តួចផ្តើមអភិវឌ្ឍន៍ ។វាគឺជាយុទ្ធសាស្ត្រមួយដើម្បីយកជ័យជំនះលើភាពលំអៀង ការអនុគ្រោះនិយមនិងវិសមភាព ។ដោយអំណាចនិងធនធានទាំងនោះ គឺភាគច្រើន

*ស្ថិតនៅក្នុង**កណ្តាប់ដៃរបស់**បុរសនៅក្នុងពេលបច្ចុប្បន្ននេះ ។ម្យ៉ាងវិញទៀតការតំរូវឱ្យមានយេនឌ័រ គឺជាស្ថានភាពសុក្រិតនិងស្វាហាប់ ដែលក្នុងនោះ ស្ត្រីនិងបុរសមានឱកាសស្មើគ្នា សិទ្ធិស្មើគ្នា អំណាចស្មើគ្នា ចែករំលែកការទទួលខុសត្រូវស្មើគ្នា មានតួនាទីស្មើគ្នានៅក្នុងគ្រួសារ ក្នុងសហគមន៍ និងនៅក្នុងសង្គម ។*

*៤ក) គោលដៅ យេនឌ័រ*

***✱ ទស្សនៈយេនឌ័រមានគោលដៅពីរ :***

**1-តំរូវការយេនឌ័រជាក់ស្តែង :** *គឺជាការឆ្លើយតបមួយចំពោះសេចក្តីត្រូវការជាចាំបាច់ភ្លាមៗនិងជាបន្ទាន់របស់ស្ត្រីដែលពាក់ពន្ធ័ទៅនឹងភាពមិនគ្រប់គ្រាន់នៅក្នុងស្ថានភាពរស់នៅ ការថែទាំសុខភាព និងការបំពេញការងាររបស់ពួកគេ ។*

*ឧទាហរណ៍ :ត្រូវតែមានការចូលរបស់នារី ក្នុងការបំពេញការងារនៅគ្រប់ស្ថាប័នរដ្ឋ ឯកជន ក្រុមហ៊ុន ។ល ។*

**2-តំរូវការយេនឌ័រជាយុទ្ធសាស្ត្រ :** *គឺជាការផ្តល់ឱកាសឱ្យស្ត្រីទទួលបាននូវ សមធម៌និងសមភាពយេនឌ័រទាក់ទងទៅនឹងពលកម្មការងារ ការបែងចែកអំណាច ការគ្រប់គ្រងនិងបញ្ហាមួយចំនួនទៀត ដូចជាសិទ្ធិខាងផ្លូវច្បាប់ អំពើហិង្សាក្នុងគ្រួសារ ប្រាក់ឈ្នួលស្មើគ្នា និងការគ្រប់គ្រងរបស់ស្ត្រីទៅលើកូនរបស់គេ ។*

*ឧទាហរណ៍ :សព្វថ្ងៃតួនាទីរបស់ស្ត្រីក្នុងការដឹកនាំ មានតិចតួចណាស់ ដូចជានៅជួររដ្ឋាភិបាល មានស្ត្រីដឹកនាំតែពីរនាក់ប៉ុណ្ណោះ ។*

**២.ច្បាប់ការពារឱ្យមានសមភាពផ្នែកភេទ :**

**ក.ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**✪ មាត្រា៤៥ :**

-ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល ។

-ការធ្វើអាជីវកម្មលើការងារស្ត្រីត្រូវហាមឃាត់ ។

-បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ក្នុងគ្រួសារ ។

-អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្មគ្រ័ចិត្តប្ដីមួយប្រពន្ធមួយ

**ㆍមាត្រា៣៦** ( កថាខណ្ឌ៣) :ការងារមេផ្ទះមានតំលៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

**ខ) ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាក្នុងសម័យអន្តរកាល**

**ㆍមាត្រា៤១** : ( អំពើបង្ករបួសដោយចេតនា)

ជនណាវាយតប់បណ្ដាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្ដោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោស ពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្ដន្ទាទោសដាក់គុកពី ១ឆ្នាំទៅ ៥ឆ្នាំ ។

-បើពិការភាពបណ្ដោះអាសន្ននោះតិចជាង៦ខែ ត្រូវផ្ដន្ទាទោសដាក់គុកជននោះពី ៦ខែ ដល់ ២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្ដន្ទាគឺដាក់គុកពី ២ខែ ទៅ ១ឆ្នាំ ។

-បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ប្រភេទទោសត្រូវកំណត់មួយជាពីរ ។

**គ).កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ និងស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌**

**ㆍមាត្រា៣**:រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញាទាំងពីរនេះ ត្រូវធានាធ្វើឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រី ក្នុងការប្រើសិទ្ធិទាំងអស់ខាងផ្នែក សិទ្ធិពលរដ្ឋ-នយោបាយ-សេដ្ឋកិច្ច-សង្គមនិងវប្បធម៌ ។

☆☆☆☆☆☆☆☆☆☆☆☆☆

មនុស្សមានសេចក្ដីថ្លៃថ្នូរនិងសិទ្ធិស្មើគ្នា



# ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ

**I.ទស្សនៈរួម :** គឺជាការប្រសើរបំផុតសំរាប់ប្រទេសកម្ពុជា ដែលមានរដ្ឋធម្មនុញ្ញ ចែងអំពីការការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។

ដូច្នេះជននានា ដែលបានទទួលការបង្កើនសមត្ថភាព តាមរយៈការអប់រំសិទ្ធិមនុស្ស គឺមិនមែនត្រឹមតែបាន យល់ដឹងហើយសម្ងំលាក់ទុកក្នុងខ្លួននោះទេ គួរគប្បីលៃលក ជួយរកមធ្យោបាយ ផ្ដល់នូវការយល់ដឹង ដល់សាច់ញាតិ ឬអ្នកជិតខាងផងដែរ ដើម្បីឱ្យគេ ចូលរួមគំនិតបង្កើតយុទ្ធសាស្ត្រសំរាប់កាត់បន្ថយការរំលោភ សិទ្ធិមនុស្ស ដែលតែងតែកើតមានជារឿយៗ នៅក្នុងភូមិ ក្នុងឃុំ ឬសហគមន៍របស់អស់លោកអ្នកផងដែរ ទើបគ្រប់ៗគ្នាមានសន្តិសុខផ្ទាល់ខ្លួន ។

ការបង្កើត ជាក្រុមស៊ីវិល( ក្រុមប្រជាពលរដ្ឋ) គឺសំរាប់ការពារផលប្រយោជន៍រួម ក្នុង ភូមិ ឃុំ របស់ខ្លួន មានន័យ ថាជាមធ្យោបាយ សំរាប់ដោះស្រាយការរំលោភសិទ្ធិមនុស្ស ក្នុងភូមិ ឃុំ របស់យើង កំពុងកើតមានហើយ ។ ចូរពិចារណា នូវពាក្យស្លោកមួយឃ្លា ដែលបាននិយាយថា" *មុននឹងឱ្យទេវតាជួយ ត្រូវជួយខ្លួនឯងជាមុនសិន*" មានន័យថា "ពង្រឹងសមត្ថភាពរបស់ខ្លួនយើងជាមុនសិន ទើបអ្នកដទៃអាចជួយយើងបាន ។ ដូច្នេះ ដើម្បីដោះ ស្រាយ គ្រប់បញ្ហាសិទ្ធិមនុស្សរបស់យើងបាន ទាល់តែតែមនុស្សទាំងអស់ ចេះគោរពគ្នាទៅវិញទៅមក ចេះ សាមគ្គីឬជួយគ្នាទៅវិញទៅមក ជួយដោះស្រាយគ្នានៅពេលមានអាសន្ន ចេះរួមគ្នាធ្វើការងារជួយជនរងគ្រោះ ដោយសារហេតុការណ៍ទាំងឡាយណាដែលកើតមាននៅក្នុងសហគមន៍ ។

អស់លោកអ្នកកុំភ្លេចថា សិទ្ធិមនុស្សត្រូវបានលើកតំកើងក៏ពិតមែន ក៏ប៉ុន្តែបើយើងមិនបានប្រើប្រាស់វា ឬមិន បានអនុវត្តវា គឺវាមាននៅតែក្នុងសៀវភៅប៉ុណ្ណោះ រីឯការរំលោភសិទ្ធិមនុស្សឬក៏រំលោភច្បាប់ទៅលើអ្នកដទៃ នៅតែមិនអាចផ្លាស់ប្តូរបានឡើយ ។ ដូច្នេះអ្វីដែលជាយុទ្ធសាស្ត្រសំខាន់នៅពេលនេះគឺចង់បានការចេះធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហានៅក្នុងសហគមន៍ តាមបែបប្រជាធិបតេយ្យ ឬក៏ការបង្កើតជាបណ្ដាញការងារ ដើម្បី

ព្យាយាម ទប់ទល់ កាត់បន្ថយ លុបបំបាត់ អំពើរំលោភសិទ្ធិមនុស្សដែលតែងតែកើតមាន ។

## II. ការបង្កើតក្រុមស៊ីវិលតាមបែបប្រជាធិបតេយ្យ

ចំណុចចំ ងៗជាយុទ្ធសាស្ត្រដើម្បីដោះស្រាយការរំលោភនោះ ជាបឋម គឺការបង្កើត ក្រុមស៊ីវិល ឬក្រុមប្រជា រដ្ឋ ដើម្បីសហការជួយដោះស្រាយការងារ ឬជួយអប់រំ អំពីអំពើអ្វីៗដែលកើតមាននៅក្នុងភូមិ ឃុំ ។ ការបង្កើតក្រុមស៊ីវិល គឺធ្វើឡើងដោយការបោះឆ្នោតដោយសេរី និងសម្ងាត់ បានសេចក្តីថា អ្នកចូលរួមនៅក្នុងវគ្គបំប៉នទាំងអស់នេះ ត្រូវបោះឆ្នោតជ្រើសរើសតំណាងក្រុមស៊ីវិលរបស់ខ្លួន ពីររូប មានប្រធានមួយរូប និងអនុប្រធានមួយរូប ។ បន្ទាប់ពីជ្រើសរើសហើយ ក្រុមស៊ីវិលនេះនឹងអាចដំណើរការបាននៅតាមមូលដ្ឋានរបស់ខ្លួន ថាតើប្រធាន គួរធ្វើអ្វី? អនុប្រធាន និងសមាជិកគួរធ្វើអ្វី? ។

អំពីតួនាទីនិងភារកិច្ចនេះ អ្នកសំរបសំរួលវគ្គនឹងជំរាបជូន លោកអ្នក អំពីកិច្ចការដែលត្រូវធ្វើ និងនីតិវិធីផ្សេងៗទៀត ទាក់ទងទៅនឹងកិច្ចការរបស់ក្រុមស៊ីវិល ដើម្បីលោកអ្នកសហការដោះស្រាយ ការរំលោភសិទ្ធិមនុស្សនៅតាមភូមិ ឃុំ អស់លោកអ្នក ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

## III. ពិភាក្សាដោះស្រាយអំពីករណីរំលោភសិទ្ធិមនុស្សដែលកើតមាននៅក្នុងមូលដ្ឋាន

សិក្ខាកាម ទាំងអស់នឹងរៀបរាប់ ប្រភេទផ្សេងៗគ្នានៃការរំលោភដែលបាននិងកំពុងកើតមានហើយ នៅក្នុងភូមិ ឃុំ របស់លោកអ្នក ហើយស្រង់ប្រភេទនៃការរំលោភទាំងនោះ ដាក់ក្នុងតារាងដូចមានខាងក្រោមនេះ :

| ល.រ | ប្រភេទនៃការរំលោភ | ទីកន្លែង(ភូមិ,ឃុំ,ស្រុក) | ចំនួន | រកដំណោះស្រាយ |
|---|---|---|---|---|
| ១. | ........................................ | ............................................ | ..... | ...................... |
| សរុប | | | | |

## IV.ការស៊ើបអង្កេតអំពីករណីរំលោភសិទ្ធិមនុស្ស

បើសិនជាការរំលោភសិទ្ធិមនុស្សមានលក្ខណៈធ្ងន់ធ្ងរ ករណីទាំងនោះត្រូវតែធ្វើការស៊ើបអង្កេត ដោយស្វែងរកពត៌មានដែលគួរឱ្យជឿទុកចិត្តបាន ហើយនីតិវិធីដែលត្រូវយកពត៌មាននោះមានដូចខាងក្រោមនេះ :

ក-តើអ្នកណាជាជនរងគ្រោះ ? ឈ្មោះ.ភេទ.អាយុ.មុខងារ.ទីលំនៅ. ទីកន្លែងកើតហេតុ ពេលវេលា.....។

ខ-តើអ្នកណាជាអ្នករំលោភសិទ្ធិមនុស្សទៅលើជនរងគ្រោះ? ឈ្មោះ.ភេទ.អាយុ.មុខងារ.ទីលំនៅ.ទីកន្លែងកើតហេតុ.ពេលវេលា.............។

គ-ហេតុអ្វីបានជាជនរងគ្រោះនោះត្រូវគេរំលោភ?(លួច-ប្លន់ -រឿងក្នុងគ្រួសារ-គំនុំផ្ទាល់ខ្លួន-គំនុំនយោបាយ.ការ ចាប់ជំរិត.ការជួញដូរ......។

ឃ-តើការរំលោភបំពានប្រភេទណាទៅដែលគេបានប្រព្រឹត្តទៅលើជនរងគ្រោះនោះ?(បោកប្រាស់.ប្រើលុយកាក់.ការប្រើប្រាស់អាវុធ ដូចជា កាំភ្លើង .គ្រាប់បែក.កាំបិតគ្រប់ប្រភេទ .ដំបង ឬឧបករណ៍ផ្សេងទៀត .....។

ង-តើមានមាត្រាច្បាប់ណាខ្លះទៅ ដែលត្រូវបានគេរំលោភបំពាននោះ?

ច-តើបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានត្រូវយកទៅកន្លែងណា ឬផ្តល់ឱ្យអ្នកណា?

## V.ការសំដែងធាក (ពីការផ្តល់ពត៌មានដល់អង្គការសិទ្ធិមនុស្ស ឬនគរបាល)

## VI.ឧបសម្ពន្ធ័សំខាន់

## ១.សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស :

**៙ មាត្រា៨ :** ជនរាល់រូប មានសិទ្ធិស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធិភាពពីតុលាការជាតិ ដែលមានសមត្ថកិច្ច ចំពោះអំពើរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ ។

**៙ មាត្រា៩ :** (កថាខណ្ឌ៤-៥)

☆ជនណាម្នាក់ដែលត្រូវគេបំបិទសិទ្ធិរបស់ខ្លួនតាមរយៈការចាប់ខ្លួន ឬឃុំខ្លួន មានសិទ្ធិប្តឹងតវ៉ាចំពោះមុខតុលាការដើម្បីឱ្យតុលាការនោះអាចនឹងកាត់ក្តីដោយមិនមានការបង្អែរបង្អង់អំពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន និងសុំឱ្យតុលាការដោះលែងពីការឃុំខ្លួននេះដោយមិនត្រឹមត្រូវតាមច្បាប់ ។

☆ជនណាម្នាក់ដែលអ្នកជារងគ្រោះពីការចាប់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិទាមទារសំណងជំងឺចិត្ត អំពីអំពើរំលោភនោះ ។

**មាត្រា២០ :** ជនណាក៏ដោយមានសិទ្ធិប្រើសេរីភាពក្នុងការប្រជុំ និងក្នុងការបង្កើតសមាគមដោយសន្តិវិធី ។ គ្មានជនណាម្នាក់ ត្រូវគេបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ ។

## ២.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**៙ មាត្រា៣២ :** ជនរាល់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។
ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា៤១ :** (ក.៥១) ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ល ។

## ៣.ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាក្នុងសម័យអន្តរកាលៈ

- **មាត្រា៣២ :** ជនណាដែលសម្លាប់មនុស្សដោយចេតនា ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋ ពី ៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

- **មាត្រា៣៣ :** ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះភេទដូចគ្នាឬមិនដូចគ្នាក៏ដោយត្រូវ មានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋ ពី ៥ឆ្នាំ ទៅ១០ឆ្នាំ ។

- **មាត្រា៤០:**(អំពើមនុស្សឃាតដោយអចេតនា) ជនណាដោយខ្វះការប្រុងប្រយត្ន័ដោយការធ្វេសប្រហែស ដោយមិនប្រយត្ន័ ឬមិនបានគោរពតាមបទបញ្ជា ធ្វើឱ្យស្លាប់ជនម្នាក់ទៀតដោយគ្មានចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយអចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

- **មាត្រា៤១ :**(អំពើបង្ករបួសដោយចេតនា ) ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។
  - -បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី ៦ខែ ដល់ ២ឆ្នាំ ។
  - -បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុកពី ១ខែ ទៅ ២ឆ្នាំ ។
  - -បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។
- **មាត្រា៣៤ :**(អំពើប្លន់) ការលួច ធ្វើដោយអំពើហិង្សា មានអាវុធឬឥតអាវុធ បណ្តាលឱ្យមានរបួសត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៣ឆ្នាំទៅ ១០ឆ្នាំ ។

## ៤). ច្បាប់ស្តីពីអំពើបង្ក្រាប អំពើពង្រត់ អំពើលក់ដូរនិងអំពើអាជីវកម្មលើមនុស្ស :

**មាត្រា៣ :** ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយវិធីលួងលោមសន្យាឱ្យប្រាក់កាសឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិត

បង្ខំគំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកមកលក់ ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ។

ចប់

បោះពុម្ពផ្សាយដោយ លីកាដូ

PUBLISHED BY

LICADHO

ឧបត្ថម្ភថវិការបស់ ដានីដា

FUNDED BY

DANIDA

# ហាមលក់

# NOT FOR SALE

រក្សាសិទ្ធិដោយអង្គការលីកាដូ

Copyright by LICADHO

បោះពុម្ព លើក ទី ៤ ចំនួន ៧០០ ក្បាល

ខែ មេសា ឆ្នាំ ២០០៤